# សង្កាត់សាលារៀនអូកឡិនដ៍

## សេចក្តីជូនដំណឹងអំពីសវនាការសាធារណៈ

## ស្តីអំពីភាពមានគ្រប់គ្រាន់នៃសៀវភៅសិក្សា ឬសម្ភារៈបង្រៀន
## សំរាប់ឆ្នាំសិក្សា 2019-2020

### ជូនចំពោះភាគីទាំងអស់ដែលមានចំណាប់អារម្មណ៍ ជាពិសេស គឺមាតាបិតា លោកគ្រូ-អ្នកគ្រូ មេដឹកនាំនៃអង្គភាពខាងចរចារគ្នា និងសមាជិកនៃសហគមន៍ ដែលមានចំណាប់អារម្មណ៍ទៅលើការងារនានានៃសង្កាត់សាលារៀនអូកឡិនដ៍។

**សូមកត់សំគាល់ថា នៅថ្ងៃពុធ ទី 25 ខែកញ្ញា ឆ្នាំ 2019** នៅក្នុងកិច្ចប្រជុំធម្មតានៃ ក្រុមប្រឹក្សាភិបាល (“ក្រុមប្រឹក្សា”) នៃសង្កាត់សាលារៀនអូកឡិនដ៍ ក្រុមប្រឹក្សានឹងបើកអង្គប្រជុំជាសាធារណៈមួយ ស្តីអំពីភាពមានគ្រប់គ្រាន់នៃសៀវភៅសិក្សា និងសម្ភារៈបង្រៀន[1]—សំរាប់ឆ្នាំសិក្សា 2019-2020។ បន្ទាប់ពីការបញ្ចប់នៃសវនការមក ក្រុមប្រឹក្សាភិបាលត្រូវធ្វើការកំណត់ តាមសេចក្តីសម្រេច ដូចមានចុះជូននៅក្នុងប្រការ (ក) និង (ខ) ខាងក្រោមនេះ។

សវនាការសាធារណៈនឹងត្រូវបានធ្វើនៅថ្ងៃទី 25 ខែកញ្ញា ឆ្នាំ 2019 នៅវេលាម៉ោង 7 ល្ងាច ឬធ្វើយ៉ាងលឿនបន្ទាប់ពីម៉ោងហ្នឹងមក  នៅក្នុងបន្ទប់ The Great Room នៃបណ្ឌលអប់រំ LaEscuelita ដែលមានអាសយដ្ឋាន 1050 2nd Avenue, Oakland, CA 94606-2291។

ក្រមអប់រំលេខ 60119 តម្រូវអោយក្រុមប្រឹក្សាភិបាល បើកសវនាការជាសាធារណៈមួយ នៅក្នុងរយៈពេលកូនសិស្សបានមកចូលរៀនបានប្រាំបីសប្តាហ៍ដំបូង ដើម្បីធ្វើការកំណត់៖

(ក) ថាតើកូនសិស្សម្នាក់ៗ នៅក្នុងសាលារៀននីមួយៗនៃសង្កាត់ មានគ្រប់គ្រាន់ ឬមានទាំងពីរដែរឬទេ នូវសៀវភៅសិក្សា ឬសម្ភារៈបង្រៀន ដែលស្របតាមស្តង់ដារមុខវិជ្ជា ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាលថ្នាក់រដ្ឋ [នៃផ្នែកអប់រំ] នៅក្នុងមុខវិជ្ជានីមួយៗដូចតទៅនេះ តាមការបានលៃទុក ដែលស្របជាមួយមាតិការ និងខួបរបស់គំរោងនៃកម្មវិធីសិក្សា ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាលថ្នាក់រដ្ឋ៖

- គណិតវិទ្យា,
- វិទ្យាសាស្ត្រ,
- ប្រវត្តវិទ្យា-សង្គមវិទ្យា,
- ភាសាវិទ្យាអង់គ្លេស រួមទាំងសមាសភាគអភិវឌ្ឍន៍ភាសាអង់គ្លេសនៃកម្មវិធីដែលបានអនុម័ត; និង

(ខ) ថាតើសិស្សម្នាក់ៗដែលបានចុះឈ្មោះចូលរៀនថ្នាក់ភាសាពិភពលោក ឬថ្នាក់សុខភាព មានគ្រប់គ្រាន់ ឬមានទាំងពីរដែរឬទេ នូវសៀវភៅសិក្សា ឬសម្ភារៈបង្រៀន ដែលស្របតាមស្តង់ដារមុខវិជ្ជា ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាលថ្នាក់រដ្ឋ [នៃផ្នែកអប់រំ] នៅក្នុងមុខវិជ្ជានីមួយៗដូចតទៅនេះ តាមការបានលៃទុក ដែលស្របជាមួយមាតិការ និងខួបរបស់គំរោងនៃកម្មវិធីសិក្សា ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាលថ្នាក់រដ្ឋ សំរាប់មុខវិជ្ជា និង៖

(គ) ភាពមានគ្រប់គ្រាន់នៃប្រដាប់ប្រដារសំរាប់មុខវិជ្ជាវិទ្យាសាស្រ្តអនុវត្ត ដែលជាប់ទាក់ទងទៅនឹងថ្នាក់អនុវត្តវិទ្យាសាស្ត្រ ដែលបានផ្តល់អោយកូនសិស្សទាំងអស់ដែលរៀនថ្នាក់ទី 9 ដល់ 12។

សេចក្តីសម្រេច និងរបាយការណ៍ (តាមការរកឃើញនានា) ដែលបានដាក់ស្នើសុំមួយច្បាប់ ស្តីអំពីភាពមានគ្រប់គ្រាន់នៃសៀវភៅសិក្សា និងសម្ភារៈបង្រៀននៃឆ្នាំសិក្សា 2019-2020 របស់សង្កាត់ គឺមានដាក់ជូន សំរាប់ធ្វើការពិនិត្យមើល តាមរយៈកំព្យូទ័រ ដែលមានដាក់ជូនអោយប្រើប្រាស់ នៅក្នុងការិយាល័យនៃក្រុមប្រឹក្សាអប់រំ និងក្នុងការិយាល័យនៃអគ្គនាយកនៃសង្កាត់សាលារៀន ដែលមានអាស័យដ្ឋាននៅ 1000 Broadway, Suite 300, Oakland, CA, 94607-4033 រវាងម៉ោង 8:30 ព្រឹកដល់ម៉ោង 4:30 រសៀល នៅថ្ងៃធ្វើការ និងមានដាក់ជូននៅថ្ងៃ ឬបន្ទាប់ពីថ្ងៃទី 13 ខែកញ្ញា ឆ្នាំ 2019 នៅគេហទំព័រ៖ http://www.ousd.org/domain/69។

s/Kyla Johnson Trammell
លេខាធិការនៃក្រុមប្រឹក្សាភិបាល
នៃសង្កាត់សាលារៀនអូកឡិនដ៍

[1] ភាពមានគ្រប់គ្រាន់នៃសៀវភៅសិក្សា ឬសម្ភារៈបង្រៀន មានន័យថាសិស្សម្នាក់ៗ រួមទាំងសិស្សអ្នករៀនអង់គ្លេសដែរ គឺមានសៀវភៅសិក្សា ឬសម្ភារៈបង្រៀន ឬមានទាំងពីរប្រភេទ ដែលស្របតាមស្តង់ដារ ក្នុងការប្រើប្រាស់នៅក្នុងថ្នាក់រៀន និងយកប្រើប្រាស់នៅឯគេហដ្ឋានផងដែរ។ ក្រមអប់រំផ្នែក 60119 (c) (1)។

OAKLAND UNIFIED SCHOOL DISTRICT
*Community Schools, Thriving Students*

| Board Office Use: **Legislative File Info.** | |
|---|---|
| File ID Number | 19-1832 |
| Introduction Date | 9/25/19 |
| Enactment Number | |
| Enactment Date | |

25 កញ្ញា 2019

ចំពោះ៖ ក្រុមប្រឹក្សាអប់រំ

ពី៖ អ្នកស្រីបណ្ឌិត Kyla Johnson-Trammell អគ្គនាយកនៃសង្កាត់សាលារៀន និងលេខាធិការនៃក្រុមប្រឹក្សាភិបាល
លោក Mr. Wesley Jacques នាយកប្រតិបត្តិផ្នែករកគំនិតថ្មីសំរាប់កម្មវិធីបង្រៀន និងសិក្សា

ប្រធានបទ៖ សវនាការសាធារណ:, របាយការណ៍ និងការអនុម័តដោយក្រុមប្រឹក្សាអប់រំ
ដំណោះស្រាយស្រាយលេខ 1920-0157 អំពីភាពមានគ្រប់គ្រាន់នៃសៀវភៅសិក្សា និងសម្ភារៈបង្រៀន
សំរាប់ឆ្នាំសិក្សា 2019-20។

(ករណី Williams)

## ស្នើសុំឱ្យចាត់វិធានការ៖

បើកសវនាការជាសាធារណ: ហើយបន្ទាប់ពីការបិទសវនាការមក នឹងមានការអនុម័តរកដំណោះស្រាយ 1920-0157 - ភាពមានគ្រប់គ្រាន់នៃសៀវភៅសិក្សា និងសម្ភារៈបង្រៀន - សំរាប់សាលារៀនទាំងអស់ ដូចបានតម្រូវឡើងដោយច្បាប់អប់រំលេខ 60119។ (ករណី Williams)

## ព្រឹត្តការណ៍កន្លងមក៖

កាលពីខែឧសភា ឆ្នាំ 2000 មក អង្គការ ACLU និងអ្នកតស៊ូមតិផ្សេងៗទៀតដើម្បីផលប្រយោជន៍ ដែលតំណាងឱ្យកូនសិស្សទូទាំងរដ្ឋបានធ្វើការប្ដឹងរដ្ឋកាលីហ្វូនញ៉ា, លោកអគ្គនាយកនៃក្រសួងណែនាំសាធារណ:, ក្រុមប្រឹក្សាអប់រំ និងក្រសួងសិក្សាធិការនៃរដ្ឋកាលីហ្វូនញ៉ា។ មូលដ្ឋាននៃបណ្ដឹងនោះ គឺថាទីភ្នាក់ងារនានាពុំបានផ្ដល់ឱ្យកូនសិស្សសាលារដ្ឋនូវសិទ្ធិស្មើភាពគ្នាក្នុងការប្រើប្រាស់សម្ភារៈបង្រៀន, ទីកន្លែងសិក្សាដែលមានលក្ខណ:សមរម្យហើយប្រកបដោយសុវត្ថិភាព និងគ្រូបង្រៀនដែលមានគុណភាពសម្បត្តិគ្រប់គ្រាន់នោះទេ។

ដំណើរការដាក់កម្ម៉ង់សម្ភារៈបង្រៀនសំរាប់ឆ្នាំសិក្សា 2019-20 គឺមានដូចតទៅនេះ៖

1. **ដាក់កម្ម៉ង់សម្ភារៈបង្រៀន៖** សម្ភារៈបង្រៀនទាំងអស់ ត្រូវបានដាក់កម្ម៉ងដោយផ្អែកលើការប៉ាន់ប្រមាណទុកជាមុនលើការចុះឈ្មោះរៀនក្នុងឆ្នាំសិក្សា 2019-20, ការឆ្លើយតបទទៅនឹងការសាកសួរព័ត៌មានអំពីការបំរើសេវាសៀវភៅសិក្សានៃសាលារៀនដែលបានកំណត់ ហើយនិងនៅក្នុងការសម្របទៅតាមកិច្ចប្រជុំមួយទល់មួយ ជាមួយនឹងអ្នកឯកទេសខាងសម្ភារៈបង្រៀន។ តារាងខាងក្រោមនេះគឺជាពេលកំណត់ដាក់កម្ម៉ង់ និងប្រគល់ឱសម្ភារៈបង្រៀននានា៖

| សម្ភារៈបង្រៀនត្រូវបានដាក់កម្ម៉ង់នៅមុន | កម្មវិធី | បានផ្ញើទៅកាន់ទីសាលារៀននានា |
|---|---|---|
| 2 កក្កដា | Math Expressions consumables | សីហា - កញ្ញា 2019 |
| 9 កក្កដា | Words Their Way consumables | សីហា - កញ្ញា 2019 |
| 8 កក្កដា | Handwriting Without Tears consumables | សីហា - កញ្ញា 2019 |
| 8 កក្កដា | Open Up Math kits and consumables | សីហា - កញ្ញា 2019 |
| 8 កក្កដា | Pearson History Books | សីហា - កញ្ញា 2019 |
| 15 កក្កដា | Adelante/Advanced Dual Language Books | សីហា - កញ្ញា 2019 |
| 8 កក្កដា | Next Generation FOSS kits and books | សីហា - កញ្ញា 2019 |
| 15 កក្កដា | ECM World Language books | សីហា - កញ្ញា 2019 |
| 2 កក្កដា | National Geographic Newcomer Books | សីហា - កញ្ញា 2019 |
| 30 មិថុនា | Systematic Instruction in Phonics, Phonemic Awareness and Sight Words | សីហា - កញ្ញា 2019 |
| 2 កក្កដា | Illustrative Mathematics Consumables | សីហា - កញ្ញា 2019 |
| 1 កក្កដា - 30 កញ្ញា | ការទិញសម្ភារៈបន្លាស់សំរាប់សម្ភារៈកម្មវិធីសិក្សាស្នូល | សីហា - កញ្ញា 2019 |

2. **រក្សាទុកកំណត់ត្រា៖** ឯកសារអ៊ិកសែល (Excel) នឹងត្រូវបានរក្សាទុកសំរាប់ទីសាលារៀននីមួយៗដែលបញ្ជាក់ពីសម្ភារៈ និងបរិមាណដែលបានដាក់កម្ម៉ង់។ ឯកសារនីមួយៗ នឹងត្រូវបានផ្តល់ទិន្នន័យថ្មីចំផុតបន្ទាប់ពីការបានដាក់កម្ម៉ង់មក។ ឯកសារដាក់កម្ម៉ង់សៀវភៅសិក្សានៃសាលារៀននីមួយៗ គឺមានផ្តល់ជូនបានតែតាមការស្នើសុំ ហើយនិងតាមការផ្ញើជូនតាមរយៈអ៊ីមែលទេ។ ក្រៅពីនេះ ដើម្បីឱ្យគោលបំណងនៃការទទួលខុសត្រូវ និងការរក្សាទុកដាក់ដាច់ដោយឡែកពីគ្នាមួយសំរាប់សាលារៀននីមួយៗ ដែលមានសម្ភារៈយកមកពីឃ្លាំងអ៊ីវ៉ាន់។ នេះរួមមានបែបបទមួយច្បាប់ ដែលត្រូវបានចុះហត្ថលេខាដោយចាងហ្វាងសាលារៀន ឬដោយអ្នកចាត់តាំង នៅក្នុងពេលដែលពួកគេមកទទួលយកសម្ភារៈម្តងៗពីឃ្លាំងដាក់អីវ៉ាន់

3. **ការស្រាវជ្រាវមតិសំរាប់សម្ភារៈបង្រៀន៖** ចាងហ្វាងសាលារៀននីមួយៗ បានជួបជាមួយនឹងអ្នកឯកទេសខាងសម្ភារៈបង្រៀន និងដើម្បីបំពេញការស្រាវជ្រាវសម្ភារៈបង្រៀន។

4. **កិច្ចប្រជុំថ្នាក់ដឹកនាំសាលារៀន៖** បុគ្គលិកនៃសង្កាត់បានជួបប្រជុំជាមួយនាយកសាលារៀននានាដែលជាប់ពាក់ព័ន្ធនឹងករណី Williams ព្រមទាំងបានឆ្លើយឆ្លងគ្នាតាមអ៊ីមែលចាប់ពីខែមីនាដល់សីហា។ គោលបំណងនៃកិច្ចប្រជុំទាំងនេះ គឺដើម្បីពិនិត្យលើចំណុចនានាដូចតទៅនេះ៖
   - ពិនិត្យលើការស្រាវជ្រាវមតិនៃករណី Williams នៅតាមទីសាលារៀនណាមួយ
   - ពិនិត្យលើទិន្នន័យនៅតាមទីសាលារៀនណាមួយ និងអំពីអ្វីៗដែលបានកម្ម៉ង់ទាន់ថ្ងៃខែរួចមកហើយ
   - ពិនិត្យលើទិន្នន័យចុះឈ្មោះរៀនតាមការប៉ាន់ប្រមាណទុកជាមុន
   - ពិនិត្យឡើងវិញលើភាសានៃការបង្រៀននៅក្នុងកម្មវិធីពីរភាសា និងកម្មវិធីបញ្ជ្រាបពីរការបញ្ចូលភាសាពីរ។
   - ពិភាក្សា៖ សេចក្តីត្រូវការបន្ថែម

5. **បែបបទស្នើសុំសៀវភៅសិក្សា៖** ចាប់ផ្តើមនៅខែសីហា ចាងហ្វាងសាលារៀនទាំងឡាយ ត្រូវទទួលខុសត្រូវលើការប្រាប់ដល់បុគ្គលិកនៃផ្នែកបំរើសេវាបង្រៀន និងរៀនសូត្រ អំពីសេចក្តីត្រូវការសៀវភៅសិក្សាថែមទៀត ផ្អែកលើចំនួនចុះឈ្មោះរៀនបន្ថែម។ ចាងហ្វាងសាលារៀន បានដាក់ទម្រង់បែបបទមួយច្បាប់ សំរាប់សៀវភៅសិក្សាដែលបញ្ជាក់ពីតួលេខនៃសៀវភៅសិក្សាដែលត្រូវការថែមទៀត។

6. **វគ្គហ្វឹកហ្វឺនចាងហ្វាងសាលារៀនសំរាប់សាលារៀនពាក់ពាន់ករណី Williams៖** បុគ្គលិកនៃការិយាល័យអប់រំប្រចាំខោណធីអាឡាមីដាដែលផ្តល់ការហ្វឹកហ្វឺននៅខែសីហា សំរាប់ចាងហ្វាងសាលារៀនពាក់ពាន់នឹងករណី Williams ពីរបៀបត្រៀមខ្លួនសំរាប់ការពិនិត្យលើបញ្ជីសៀវភៅសិក្សា Williams នៃការិយាល័យអប់រំប្រចាំខោណធីអាឡាមីដា ដែលនឹងមកដល់នាពេលខាងមុខ។

7. **ការជម្រះបញ្ជី MOCK៖** សមាជិកបុគ្គលិកនៃការិយាល័យកណ្តាលមកពីនាយកដ្ឋានខុសៗគ្នា បានធ្វើការជម្រះបញ្ជី MOCK នៅតាមទីសាលារៀនទាំងអស់ដែលជាប់ពាក់ពាន់នឹងករណី Williams។

8. **ការគាំទ្រតាមរយៈទូរស័ព្ទ៖** បុគ្គលិកផ្នែកការសិក្សា និងផ្នែកបង្រៀនតាមរបៀបថ្មី ព្រមទាំងការិយាល័យបណ្តាញ បានសហការគ្នាក្នុងការធានាអោយនាយកសាលារៀននានា ទទួលបាននូវការឧបត្ថម្ភគាំទ្រមួយទល់មួយ តាមរយៈទូរស័ព្ទ ពីដើមដល់ចុងបញ្ចប់នៃដំណើរការ Williams។

9. **សេចក្តីរំលឹកតាមរយៈអ៊ីមែល៖** ចាងហ្វាងសាលារៀន នឹងត្រូវបានផ្ញើជូននូវសេចក្តីរំលឹកតាមរយៈអ៊ីមែលយ៉ាងទៀងទាត់ អំពីថ្ងៃខែផុតកំណត់ និងការផ្តល់ទិន្នន័យថ្មីបំផុតអំពី Williams។

## ការពិភាក្សា៖

លទ្ធផលនានាចេញពីការស្ទង់មតិមកទល់ពេលនេះ បង្ហាញឱ្យឃើញថា សាលារៀនទាំងអស់មានសៀវភៅសិក្សា និង/ឬ សម្ភារៈសិក្សាគ្រប់គ្រាន់ ដូចបានតម្រូវឡើងដោយច្បាប់ SB 550។ ការស្ទង់មតិនេះ នឹងត្រូវបានបញ្ចប់នៅថ្ងៃទី 27 ខែកញ្ញា ឆ្នាំ 2018។

## ការប៉ះពាល់ហរិញ្ញវត្ថុ៖

សំរាប់ឆ្នាំសារពើពន្ធ 2019-20, ថវិកាផ្លូវការសំរាប់សៀវភៅសិក្សា / សម្ភារៈបង្រៀន គឺមានដូចតទៅនេះ៖

| ថវិការ | ថវិការផ្លូវការ | ការចំណាយគិតត្រឹមថ្ងៃទី 12 ខែកញ្ញា 2019 |
|---|---|---|
| Lottery | 1,400,000 | 1,400,000 |
| Supplemental and Concentration | 1,138,104 | 759,435 |
| Grants | 110,000 | 110,000 |

## អនុសាសន៍៖

បើកសវនាការជាសាធារណៈ និងបន្ទាប់ពីការបិទសវនាការមក អនុម័តដំណោះស្រាយ 1920-0157 - ភាពមានគ្រប់គ្រាន់នៃសៀវភៅសិក្សា និងសម្ភារៈបង្រៀន - សំរាប់សាលារៀនទាំងអស់ ដូចបានតម្រូវឡើងដោយច្បាប់អប់រំលេខ 60199។ (ករណី Williams)។

ឯកសារភ្ជាប់មកជាមួយ៖ ដំណោះស្រាយលេខ 1920-0157

ដំណោះស្រាយ
នៃ
ក្រុមប្រឹក្សាគ្រប់គ្រង
នៃ
សង្កាត់សាលារៀនអូកឡិនដ៍
ដំណោះស្រាយលេខ 1920-0157

ភាពមានគ្រប់គ្រាន់នៃសៀវភៅសិក្សា ឬសម្ភារៈបង្រៀន
សំរាប់ឆ្នាំសិក្សា 2019-20
(ក្រមអប់រំលេខ 60119 និង 5 CCR 9531)

ខណ:ដែល ក្រុមប្រឹក្សាគ្រប់គ្រងនៃសង្កាត់សាលារៀនអូកឡិនដ៍ ដើម្បីឱ្យអនុលោមតាមតម្រូវការនានានៃក្រមអប់រំលេខ 60119 ដែលបានបើកសវនាការជាសាធារណ:មួយនៅថ្ងៃទី 25 ខែកញ្ញា ឆ្នាំ 2019 នៅម៉ោង 5:30 ល្ងាច ឬដែលបានបើកយ៉ាងលឿនបន្ទាប់ពីពេលហ្នឹងដើម្បីស្តាប់រឿងរ៉ាវនោះមក ដែលបានធ្វើនៅ ឬមុនរយ:ពេលចូលរៀន និងរយ:ពេលប្រាំបីសប្តាហ៍ (នៅចន្លោះថ្ងៃដំបូងដែលកូនសិស្សចូលរៀន និងសប្តាហ៍ទីប្រាំបី ចាប់ពីថ្ងៃហ្នឹងមក) ហើយដែលមិនបានធ្វើនៅ ឬបន្ទាប់ពីម៉ោងរៀន; និង

ខណ:ដែល ក្រុមប្រឹក្សាគ្រប់គ្រងបានផ្តល់ដំណឹងជូនយ៉ាងហោចណាស់ចំនួនដប់ (10) ថ្ងៃ អំពីសវនាការជាសារធារណ: ដែលបានបិទប្រកាស់នៅតាមទីសាធារណ: យ៉ាងហោចណាស់ ឱ្យបានបីកន្លែងក្នុងសង្កាត់ ដែលក្នុងនោះមានការបញ្ជាក់ពីពេលវេលា ពីទីកន្លែងមួយ និងពីគោលបំណងនៃសវនាការ:; និង

ខណ:ដែល ក្រុមប្រឹក្សាគ្រប់គ្រងបានជំរុញឱ្យមានាការចូលរួមក្នុងសវនាការជាសាធារណ:ពីសំណាក់មាតាបិតា គ្រូបង្រៀន ប្រជាសហគមន៍ និងអ្នកដឹកនាំក្រុមចរចារ; និង

ខណ:ដែល ព័ត៌មានត្រូវបានផ្តល់ជូនជាលំអិតថែមទៀតនៅក្នុងសវនាការជាសាធារណ:អំពីសៀវភៅសិក្សា និងសម្ភារ:បង្រៀនដែលបានផ្តល់ឱ្យកូនសិស្សទាំងអស់ រួមទាំងកូនសិស្សអ្នករៀនអង់គ្លេស ក្នុងសង្កាត់សាលារៀនអូកឡិនដ៍; និង

ខណ:ដែល និយមន័យនៃ «សៀវភៅសិក្សា ឬសម្ភារ:បង្រៀនគ្រប់គ្រាន់» មានន័យថា កូនសិស្សម្នាក់ៗរួមទាំងអ្នករៀនអង់គ្លេសផងដែរនោះ សុទ្ធតែមានសៀវភៅសិក្សា ឬសម្ភារ:បង្រៀន ឬមានទាំងពីរ ដើម្បីប្រើប្រាស់ក្នុងថ្នាក់រៀន និងយកទៅរៀននៅឯផ្ទះ; និង

ខណ:ដែល និយមន័យ នៅចន្លោះឆ្នាំសារពើពន្ធ 2008-09 និង 2019-20 នៃ «ការមានសៀវភៅសិក្សា ឬសម្ភារ:បង្រៀនគ្រប់គ្រាន់» គឺមានន័យដូចនេះផងដែរ ថាកូនសិស្សទាំងអស់ដែលមានឈ្មោះរៀនថ្នាក់ដូចគ្នា ក្នុងសង្កាត់សាលារៀនអូកឡិនដ៍ សុទ្ធតែមានសៀវភៅសិក្សា ឬសម្ភារ:បង្រៀន តាមស្តង់ដារចេញពីខួបនៃការអនុម័តដូចគ្នា; និង;

ខណ:ដែល ភាពមានគ្រប់គ្រាន់នៃសៀវភៅសិក្សា និងសម្ភារ:បង្រៀន ត្រូវបានផ្តល់ឱ្យកូនសិស្សម្នាក់ៗ រួមទាំងកូនសិស្សអ្នករៀនអង់គ្លេសស្របទៅតាមស្តង់ដារនៃមុខវិជ្ជាសិក្សា ហើយស្របតាមខួប និងមាតិកានៃគំរោងកម្មវិធីសិក្សាក្នុងមុខវិជ្ជាដូចតទៅនេះ៖

គណិតសាស្ត្រ៖

*(នៅឆ្នាំសិក្សា 2013-2014 ការអនុម័តយកសៀវភៅគណិតសាស្ត្រនៃសង្កាត់សាលារៀនអូកឡិនដ៍ ត្រូវបានធ្វើឡើងសំរាប់កូនសិស្សថ្នាក់ K-5)។ សៀវភៅសិក្សាត្រូវបានជាវសម្រាប់ឆ្នាំសិក្សា 2014-15។ នៅឆ្នាំ 2018 សង្កាត់ OUSD បានអនុម័តយកសៀវភៅគណិតវិទ្យាគំរូសម្រាប់អនុវិទ្យាល័យ។)*

| កំរិតថ្នាក់ | មុខវិជ្ជា | ក្រុមហ៊ុនបោះពុម្ពសៀវភៅ |
|---|---|---|
| ថ្នាក់ TK/K | Math Expressions | Houghton Mifflin Harcourt |
| 1 | Math Expressions | Houghton Mifflin Harcourt |
| 2 | Math Expressions | Houghton Mifflin Harcourt |
| 3 | Math Expressions | Houghton Mifflin Harcourt |
| 4 | Math Expressions | Houghton Mifflin Harcourt |
| 5 | Math Expressions | Houghton Mifflin Harcourt |
| 6 | Math 6 Teach to One | New Classroom-Innovation Partners |
| 6 | Course 1 Numbers to Algebra | Holt, Reinhart, Wilson |
| 7 | Math 7 Teach to One | New Classroom-Innovation Partners |
| 7 | Pre-Algebra | Pearson – Prentice Hall |
| 8 | Math 8 Teach to One | New Classroom-Innovation Partners |
| 8 | Algebra I | Holt, Reinhart, Wilson |
| 6 – 8 | Springboard course 1-3 | Collegeboard |
| 9 – 12 | Springboard Algebra I | Collegeboard |
| 9 – 12 | Springboard Geometry | Collegeboard |
| 9 – 12 | Springboard Algebra 2 | Collegeboard |
| 9 – 12 | Springboard Pre-Calculus | Collegeboard |
| 9 – 12 | Algebra I | Pearson – Prentice Hall |
| 9 – 12 | Geometry | Holt, Reinhart, Wilson |
| 9 – 12 | Probability & Statistics: The Basic Practice of Statistic | Freeman |
| 9 – 12 | AP Statistics: The Practice of Statistics | Freeman |
| 9 – 12 | Algebra 2 | Holt, Reinhart, Wilson |
| 9 – 12 | Pre-Calculus-Graphical, Numerical, Algebraic | Pearson-Addison Wesley |
| 9 – 12 | Calculus-Graphical, Numerical, Algebraic | Pearson-Addison Wesley |

វិទ្យាសាស្ត្រ៖

*(នៅឆ្នាំសិក្សា 2018 សង្កាត់ OUSD បានទទួលយកសម្ភារៈបង្រៀនស្របតាមស្តង់ដារវិទ្យាសាស្ត្រជំនាន់ក្រោយ សម្រាប់ថ្នាក់ K-5 និង នៅឆ្នាំ 2019 សម្រាប់ថ្នាក់ទី 6-8។ សៀវភៅសិក្សាកំរិតវិទ្យាល័យត្រូវបានអនុម័តនៅឆ្នាំ 2006-2007។)*

| កំរិតថ្នាក់ | មុខវិជ្ជា | ក្រុមហ៊ុនបោះពុម្ពសៀវភៅ |
|---|---|---|
| ថ្នាក់ TK | FOSS Modules - Fabric (for the Physical Science rotation, only) | Foss/Delta Education |
| ថ្នាក់ K | FOSS Module - Life (Animals Two by Two); Foss Kit-Earth (Trees & Weather); Foss Kit-Physical (Materials & Motion) | Foss/Delta Education |
| 1 | FOSS Module - Life (Plants & Animals); Foss Kit-Earth (Air & Weather); Foss Kit-Physical (Sound and Light) | Foss/Delta Education |
| 2 | FOSS Modules - Life (Insects & Plants); Foss Kit-Earth (Pebbles, Sand & Silt); Foss Kit-Physical (Solids and Liquids) | Foss/Delta Education |
| 3 | FOSS Modules - Life (Structures of Life); Foss Kit-Earth (Water & Climate); Foss Kit-Physical (Motion and Matter) | Foss/Delta Education |
| 4 | FOSS Modules - Life (Environments); Foss Kit-Earth (Soils, Rocks, and Landforms); Foss Kit-Physical (Energy) | Foss/Delta Education |
| 5 | FOSS Modules - Physical (Living Systems); Foss Kit-Physical (Earth and Sun); Foss Kit-Physical (Mixtures & Solutions) | Foss/Delta Education |
| 6 | FOSS Modules - Weather and Water, Diversity of Life, Human Systems Interactions | Foss/Delta Education |
| 7 | FOSS Modules - Chemical Interactions, Earth History, Populations and Ecosystems | Foss/Delta Education |
| 8 | FOSS Modules - Heredity and Adaptation, Electromagnetic Force, Gravity and Kinetic Energy, Waves, Planetary Science | Foss/Delta Education |
| 9 – 12 | Biology: Biology by Nowicki (lab class) | McDougall Littell |
| 9 – 12 | Biology AP: Biology by Campbell (lab class) | Pearson |
| 9 – 12 | Chemistry (lab class) | Pearson |
| 9 – 12 | Chemistry AP: Chemistry the Central Science (lab class) | Pearson |
| 9 – 12 | Physics: Conceptual Physics by Hewitt (lab class) | Pearson |
| 9 – 12 | Physics AP: Physics by Cutnell & Johnson (lab class) | People Press |
| 9 – 12 | Physiology: Essentials of Anatomy & Physiology (lab class) | Pearson |
| 9 – 12 | Environmental Science: A Study of Interrelationships | McGraw Hill |
| 9 – 12 | Environmental Science AP: Living in the Environment (lab) | Thompson |
| 9 – 12 | Geology: Earth Science, 11th Edition | Pearson |

## គ្រឿងបរិក្ខាសំរាប់ថ្នាក់វិទ្យាសាស្ត្រពិសោធ

*ថ្នាក់ទី 9 -12*

| កំរិតថ្នាក់ | មុខវិជ្ជា | ក្រុមហ៊ុនបោះពុម្ពសៀវភៅ |
|---|---|---|
| 9 – 12 | Science Lab: Bunson Burner | N/A |
| 9 – 12 | Science Lab: Dissecting Kit | N/A |
| 9 – 12 | Science Lab: Goggles | N/A |
| 9 – 12 | Science Lab: Hot Plate | N/A |
| 9 – 12 | Science Lab: Microscope | N/A |
| 9 – 12 | Science Lab: Slides & Cover Slips | N/A |
| 9 – 12 | Science Lab: Scale Triple Beam or Digital | N/A |
| 9 – 12 | Science Lab: Graduated Cylinder 1 Liter | N/A |
| 9 – 12 | Science Lab: Graduated Cylinder 5 ml | N/A |
| 9 – 12 | Science Lab: Graduated Cylinder 10 ml | N/A |
| 9 – 12 | Science Lab: Graduated Cylinder 100 ml | N/A |
| 9 – 12 | Science Lab: Flasks | N/A |
| 9 – 12 | Science Lab: Beakers 10ml | N/A |
| 9 – 12 | Science Lab: Beakers 100 ml | N/A |
| 9 – 12 | Science Lab: Beakers 250 ml | N/A |
| 9 – 12 | Science Lab: Beakers 500 ml | N/A |
| 9 – 12 | Science Lab: Test Tubes Small | N/A |
| 9 – 12 | Science Lab: Test Tubes Large | N/A |
| 9 – 12 | Science Lab: Pipettes | N/A |

## ប្រវត្តសាស្ត្រ-សង្គមវិទ្យា៖

*(នៅឆ្នាំសិក្សា 2005-2006 ការអនុម័តយកសៀវភៅសង្គមវិទ្យានៃសង្កាត់សាលារៀនអូកឡិនដ៍ ត្រូវបានធ្វើឡើងសំរាប់កូនសិស្សថ្នាក់ទី 4-12។ សៀវភៅសិក្សាត្រូវបានជាវទុកសំរាប់ឆ្នាំសិក្សា 2006-2007។ នៅឆ្នាំសិក្សា 2006-2007 ការអនុម័តយកសៀវភៅសង្គមវិទ្យានៃសង្កាត់សាលារៀនអូកឡិនដ៍ ត្រូវបានធ្វើឡើងសំរាប់កូនសិស្សថ្នាក់ K-3។ សៀវភៅសិក្សា ត្រូវបានជាវទុកសំរាប់ឆ្នាំសិក្សា 2007-2008។)*

| កំរិតថ្នាក់ | មុខវិជ្ជា | ក្រុមហ៊ុនបោះពុម្ពសៀវភៅ |
|---|---|---|
| ថ្នាក់ TK/K | Our World, Now & Long Ago Big Book | Harcourt |
| ថ្នាក់ TK/K | Our World, Now & Long Ago Big Book, Spanish | Harcourt |
| 1 | A Child's View Big Book | Harcourt |
| 1 | A Child's View Big Book, Spanish | Harcourt |
| 2 | People We Know | Harcourt |
| 2 | People We Know, Spanish | Harcourt |
| 3 | Our Communities | Harcourt |
| 3 | Our Communities, Spanish | Harcourt |
| 4 | California, A Changing State | Harcourt |
| 4 | California, A Changing State, Spanish | Harcourt |
| 5 | Making a New Nation | Harcourt |
| 5 | Making a New Nation, Spanish | Harcourt |
| 6 | Ancient Civilizations | Harcourt |
| 7 | Medieval to Early Modern Times | Harcourt |
| 8 | United States History | Harcourt |
| 9 – 12 | World History: The Modern World c.2007 | Pearson |
| 9 – 12 | World History AP: Traditions & Encounters c.2006 | McGraw Hill |
| 9 – 12 | US History: American Anthem | Holt, Reinhart, Wilson |
| 9 – 12 | US History AP: American Past & Present 7th Edition | Holt, Reinhart, Wilson |
| 9 – 12 | Magruder's American Government | Pearson |
| 9 – 12 | American Government AP: Continuity & Change | Pearson |
| 9 – 12 | Contemporary Economics | Thompson |

**ភាសាសាស្ត្រ / អង់គ្លេស៖**

*(នៅឆ្នាំសិក្សា 2014-2015 និង 2015-2016 ការអនុម័តយកសៀវភៅភាសាសាស្ត្រអង់គ្លេសនៃសង្កាត់សាលារៀនអូកឡិនដ៍ ត្រូវបានធ្វើឡើងសំរាប់កូនសិស្សថ្នាក់ K-5។ សៀវភៅសិក្សាត្រូវបានជាវទុកសំរាប់ឆ្នាំសិក្សា 2015-2016 និង 2016-2017។*
*(នៅឆ្នាំសិក្សា 2015-2016 ការអនុម័តយកសៀវភៅភាសាសាស្ត្រអង់គ្លេសនៃសង្កាត់សាលារៀនអូកឡិនដ៍ ត្រូវបានធ្វើឡើងសំរាប់កូនសិស្សថ្នាក់ទី 6-8។ សៀវភៅសិក្សាត្រូវបានជាវទុកសំរាប់ឆ្នាំសិក្សា 2016-2017។)*
*(នៅឆ្នាំសិក្សា 2003-2004 ការអនុម័តយកសៀវភៅភាសាសាស្ត្រអង់គ្លេសនៃសង្កាត់សាលារៀនអូកឡិនដ៍ ត្រូវបានធ្វើឡើងសំរាប់កូនសិស្សថ្នាក់ទី 9-12។ សៀវភៅសិក្សាត្រូវបានជាវទុកសំរាប់ឆ្នាំសិក្សា 2004-2005។)*

| កំរិតថ្នាក់ | មុខវិជ្ជា | ក្រុមហ៊ុនបោះពុម្ពសៀវភៅ |
|---|---|---|
| ថ្នាក់ TK/K | Classroom Leveled Library--English | Booksource |
| ថ្នាក់ TK/K | Classroom Leveled Library--Spanish | Follett |
| ថ្នាក់ TK/K | Handwriting Without Tears | HWT |
| 1--5 | Classroom Leveled Library--English | Booksource |
| | Classroom Leveled Library--Spanish | Follett |
| 6 | កម្មវិធីសិក្សា Expeditionary Learning's EngageNY៖ *Lightning Thief*, *Bud, Not Buddy*, *Dragonwings*, *Frightful's Mountain*, *Good Masters! Sweet Ladies! Voices from a Medieval Village*, *World Without Fish*, *Flush* | សៀវភៅប្រលោមលោក |
| 7 | កម្មវិធីសិក្សា Expeditionary Learning's EngageNY៖ *A Long Walk to Water*, *Lyddie*, *Pygmalion*, *The Big Thirst: The Secret Life and Turbulent Future of Water* | សៀវភៅប្រលោមលោក |
| 8 | កម្មវិធីសិក្សា Expeditionary Learning's EngageNY៖ *Inside Out & Back Again*, *To Kill a Mockingbird (50th Anniversary Edition), A Midsummer Night's Dream*, *Unbroken: A World War II Story of Survival, Resilience and Redemption*, *A Might Long Way: My Journey to Justice at Little Rock Central High School, Little Rock Girl 1957: How a Photograph Changed the Fight for Integration*, *The Omnivore's Dilemma: The Secrets Behind What You Eat, Young Readers Edition* | សៀវភៅប្រលោមលោក |
| 6-8 | English 3D | HMH |
| 6-8 | National Geographic Inside the USA | Cengage |
| 6-8 | National Geographic Fundamentals | Cengage |
| 6-8 | Literature & Language Arts (ELD 1-5) | Holt |
| 9 | Literature & Language Arts: 3rd Course | Holt |
| 9 | *Romeo and Juliet*, *To Kill a Mockingbird* | សៀវភៅប្រលោមលោក |
| 9 | Springboard Level 4 | CollegeBoard |
| 10 | Literature & Language Arts: 4th Course | Holt |
| 10 | *Purple Hibiscus*, *Things Fall Apart* | សៀវភៅប្រលោមលោក |
| 10 | Springboard Level 5 | CollegeBoard |
| 11 | Literature & Language Arts: 5th Course | Holt |
| 11 | *Huckleberry Finn*, *Fences*, *Their Eye's are Watching God* | សៀវភៅប្រលោមលោក |
| 11 | Springboard Level 6 | CollegeBoard |
| 12 | Literature & Language Arts: 6th Course | Holt |
| 12 | Springboard Senior English | CollegeBoard |
| 9 – 12 | English 3 AP: Norton Reader | Peoples Press |
| 9 – 12 | English 4 AP: Bedford's Anthology | VHPS |
| 9 – 12 | English 4 AP: Perrine's Sound & Sense | Thompson |

## ថ្នាក់អភិវឌ្ឍភាសាអង់គ្លេស / ថ្នាក់រៀនសំរាប់សិស្សចំណូលថ្មី ឬសិស្សអ្នករៀនភាសាអង់គ្លេសសំរាប់រយៈពេលយូរ

| កំរិតថ្នាក់ | មុខវិជ្ជា | ក្រុមហ៊ុនបោះពុម្ពសៀវភៅ |
|---|---|---|
| 6 – 8 | ELD 5/LTEL: English 3D | HMH |
| 6 – 8 | ELD 1: National Geographic Inside the USA | Cengage |
| 6 – 8 | ELD 1-5: National Geographic Edge | Cengage |
| 6 – 8 | ELD 1-5: Holt Literature and Language Arts | Holt |
| 9 – 12 | ELD 5/LTEL: English 3D | HMH |
| 9 – 12 | ELD 1: National Geographic Inside the USA | Cengage |
| 9 – 12 | ELD 1-5: National Geographic Edge | Cengage |

## ភាសាពិភពលោក៖

*(នៅឆ្នាំសិក្សា 2015-2016, ការអនុម័តយកសៀវភៅភាសាពិភពលោកនៃសង្កាត់សាលារៀនអូកឡិនដ៍ ត្រូវបានធ្វើឡើងសំរាប់កូនសិស្ស ថ្នាក់ទី 6-12។ សៀវភៅសិក្សាត្រូវបានជាវទុកសំរាប់ឆ្នាំសិក្សា 2016-2017។)*

| កំរិតថ្នាក់ | មុខវិជ្ជា | ក្រុមហ៊ុនបោះពុម្ពសៀវភៅ |
|---|---|---|
| 6 – 8 | Spanish A/B: Adelante A/B | Holt |
| 6 – 8 | Spanish I: En Espanol | McDougall Littell |
| 6 – 8 | French A/B: Bon Voyage | Glencoe |
| 6 – 8 | French I: Discovering French Bleu | McDougall Littell |
| 9 – 12 | Spanish I: Que Chevere | EMC |
| 9 – 12 | Spanish II: Que Chevere | EMC |
| 9 – 12 | Spanish III: Que Chevere | EMC |
| 9 – 12 | Spanish IV: Que Chevere | EMC |
| 9 – 12 | EPH II: Imagina | Vista Higher Learning |
| 9 – 12 | EPH III: Imagina | Vista Higher Learning |
| 9 – 12 | EPH IV: Abriendo Paso Lecture | Prentice Hall |
| 9 – 12 | EPH IV: Abriendo Paso Grammatica | Prentice Hall |
| 9 – 12 | EPH V: Abriendo Puertas Vol.1 | McDougall Littell |
| 9 – 12 | EPH V: Abriendo Puertas Vol.2 | McDougall Littell |
| 9 – 12 | French IV: Tresors du Temps | Glencoe |
| 9 – 12 | French I: T’es Branche | EMC |
| 9 – 12 | French II: T’es Branche | EMC |
| 9 – 12 | French III: T’es Brance | EMC |
| 9 – 12 | AP French: Themes | Vista Higher Learning |
| 9 – 12 | AP Spanish Literature: Reflexiones | Pearson |
| 9 – 12 | AP Spanish Language: Temas | Vista Higher Learning |
| 9 – 12 | Mandarin I-III: Zhen Bang Levels 1-3 | EMC |

ឥឡូវនេះ ហេតុដូច្នេះ នឹងត្រូវបានដោះ ថា ក្រុមប្រឹក្សាគ្រប់គ្រងនៃសង្កាត់ តាមរយៈនេះ សូមប្រកាស់ស្វែងរក និងអនុម័តរបាយការណ៍ នៅទីនេះ ដោយថ្លែងថាសង្កាត់ សំរាប់ឆ្នាំសិក្សា 2019-20 បានផ្តល់ឱ្យកូនសិស្សម្នាក់ៗ នូវសៀវភៅសិក្សា និងសម្ភារៈបង្រៀនគ្រប់គ្រាន់ ដែលមានលក្ខណៈស្របតាមស្តង់ដារមុខវិជ្ជាសិក្សា និងស្របតាមខួប និងអ្វីៗដែលមាននៅក្នុងគំរោងកម្មវិធីសិក្សា។

បានបោះឆ្នោតអនុម័ត និងទទួលយក នៅថ្ងៃទី 25 ខែកញ្ញា នៅក្នុងកិច្ចប្រជុំធម្មតាមួយនៃក្រុមប្រឹក្សាគ្រប់គ្រង តាមការបោះឆ្នោតដូចតទៅនេះ៖

បោះឆ្នោតគាំទ្រ៖

បោះឆ្នោតបដិសេធ៖

បោះឆ្នោតអនុបវាទ៖

អវត្តមាន៖

ខ្ញុំបាទ/នាងខ្ញុំ តាមរយៈនេះ សូមបញ្ជាក់ថា អ្វីៗដែលបានជំរាបជូននៅខាងលើនេះ គឺជាដំណោះស្រាយពេញលេញ ពិតប្រាកដ និងត្រឹមត្រូវ ដែលបានអនុម័តនៅក្នុងកិច្ចប្រជុំធម្មតានៃក្រុមប្រឹក្សាគ្រប់គ្រងនៃសង្កាត់សាលារៀនអូកឡិនដ៍ ដែលបានធ្វើនៅថ្ងៃទី 25 ខែកញ្ញា ឆ្នាំ 2019៕

ធ្វើនៅថ្ងៃទី 25 ខែកញ្ញា ឆ្នាំ 2019

____________________________

Kyla Johnson-Trammell
លេខាធិការ, ក្រុមប្រឹក្សាភិបាល
សង្កាត់សាលារៀនអូកឡិនដ៍